ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការថ្នាក់ជាតិ
# សំរាប់
# ការងារអប់រំក្រៅប្រព័ន្ធ
# ២០០៤-២០១៥

# ផែនការថ្នាក់ជាតិ

# សំរាប់

# ការងារអប់រំក្រៅប្រព័ន្ធ

# ២០០៤ -២០១៥

# មាតិកា


១. សេចក្តីផ្តើម

២. អក្ខរកម្មវិជ្ជាជីវៈសំរាប់មនុស្សពេញវ័យ

៣. ការអប់រំសមមូលសំរាប់បឋមសិក្សានិងមធ្យមសិក្សា

៤. ជំនាញរកប្រាក់ចំណូលរយៈពេលខ្លី

៥. កម្មវិធីក្រោយអក្ខរកម្មសំរាប់មនុស្សពេញវ័យ

៦. កម្មវិធីអប់រំគ្រួសារដើម្បីអភិវឌ្ឍន៍កុមារតូច

៧. មជ្ឈមណ្ឌលសិក្សាសហគមន៍

៨. ការកសាងសមត្ថភាពសំរាប់ការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព

៩. គំរោងថវិកា

# ១. សេចក្ដីផ្ដើម

## ១.១ ទំហំនៃកិច្ចប្រឹងប្រែង

គេមិនបានបដិសេធន៍នូវទំហំ និង វិសាលភាពនៃតំរូវការអប់រំក្នុងប្រទេសកម្ពុជាឡើយ ទោះបីជាស្ថិតិជាក់ស្ដែងមិនច្បាស់លាស់ក៏ដោយ។ ដោយយោងទៅលើជំរឿននាឆ្នាំ១៩៩៨ ប្រជាជនដែលមានអាយុ១៥ឆ្នាំឡើងទៅចំនួន៣៧% គឺជាអក្ខរជន (តួលេខនឹងកើនឡើងដល់៦៣% បើសិនជាគេរាប់បញ្ចូលទាំងអត្រានៃជនពាក់កណ្ដាលអក្ខរកម្ម ) ដោយក្នុងនោះមានចំនួនស្ត្រីពី១៥-២០% ដែលតួលេខនេះបង្ហាញថាអនក្ខរ ជនជាស្ត្រីភេទមានចំនួនខ្ពស់ជាងបុរស ហើយតួលេខនៃចំនួនអនក្ខរជនតំបន់ជនបទខ្ពស់ជាងតំបន់ទីក្រុងប្រមាណ១៥% ។ លើសពីនោះទៅទៀតចំនួនអាយុនៃអនក្ខរជនខ្ពស់បំផុតគឺ៥០ឆ្នាំឡើងទៅ ដែលក្នុងនោះចំនួនដ៏ច្រើនលើសលប់គឺស្ថិតក្នុងវ័យចិញ្ចឹមកូន និងរកប្រាក់ចិញ្ចឹមគ្រួសារ ដែលអាយុរបស់ពួកគេស្ថិតក្នុងចន្លោះចាប់ពី ១៥-៤៥ឆ្នាំ ។ ក្នុងពេលចុះឈ្មោះចូលរៀន សាលាបឋមសិក្សាសំរាប់ថ្នាក់ជាតិប្រព្រឹត្តទៅបានយ៉ាងល្អប្រសើរដោយមានចំនួនក្មេងប្រុស ៩០% និងក្មេងស្រី ៨៤%នោះ អត្រាក្មេងឡើងថ្នាក់ដល់ថ្នាក់ទី៥ធ្លាក់នៅសល់ត្រឹមតែ៤៥% ប៉ុណ្ណោះ ហើយអត្រាត្រួតថ្នាក់មាន២២% ហើយការពិតមានតែសាលារៀនចំនួន៥២% ប៉ុណ្ណោះ ដែលមានកំរិតថ្នាក់ពេញលេញដល់ថ្នាក់ទី៦ ។ មិនមានភាពច្បាស់លាស់អំពីចំនួនកុមារប៉ុន្មានដែលបោះបង់ការសិក្សានៅត្រឹមថ្នាក់ទី៦ ដែលជាកំរិតថ្នាក់ដែលគេអាចធ្វើការសន្និដ្ឋានថា កុមារទាំងនោះបានសំរេចនូវសមត្ថភាពជាមូលដ្ឋាន ផ្អែកលើប្រសិទ្ធិភាពនៃកម្មវិធីបឋមសិក្សាដែលផ្ដល់នូវមូលដ្ឋានដ៏រឹងមាំមួយក្នុងជំនាញដោះស្រាយបញ្ហា, ទំនាក់ទំនង, ការរៀបចំស្ថានភាពរស់នៅ រឺងជំនាញដែលពាក់ព័ន្ធនឹងពិភពការងារមិនទាន់ត្រូវបានគេសាកល្បងនៅឡើយ។ មានសិស្សតែ ១៩% ប៉ុណ្ណោះ ដែលក្នុងនោះមានសិស្សស្រី១៦% ដែលបានឡើងទៅរៀននៅមធ្យមសិក្សាបឋមភូមិ ។

ភាពខុសគ្នាក្នុងចំនោមប្រជាជន បានបន្ថែមអោយមានវិបត្តិកាន់តែធន់ធ្ងរឡើងៗ ។ អត្រាចុះឈ្មោះចូលរៀនក្នុងចំណោមកុមារជនជាតិភាគតិចត្រូវបានគេប៉ាន់ប្រមាណថាមានត្រឹមតែ៤០% ប៉ុណ្ណោះនេះបើគិតតាមមធ្យមភាគថ្នាក់ជាតិ ហើយគំលាតយេនឌ័រក៏មានក្នុងនេះផងដែរ ។ ការចូលរៀនរបស់កុមារី និង ស្ត្រីនៅមានកំរិតនៅថ្នាក់អប់រំមូលដ្ឋាន និងការថែទាំសុខភាពបឋមត្រូវបានគេដាក់ទន្ទឹមគ្នាជាមួយនឹងលទ្ធភាពមានកំរិតក្នុងការរកប្រាក់ចំណូលដែលមានស្ថេរភាពឥណទាន និង ការការពារដោយស្របច្បាប់ ។ ទាំងនេះហើយដែលជាចំនុចបន្ថុចបង្អាក់ពួកគេក្នុងការប្រើប្រាស់នូវឱកាសដ៏ពេញលេញមួយរបស់ពួកគេ។មានស្ត្រី១២% ដែលមានអាយុលើស២៥ឆ្នាំ បានទទួលការអប់រំខ្ពស់ជាងកំរិតបឋមសិក្សាហើយដោយផ្អែកលើការទទួលបាននូវការអប់រំនេះពួកគេអាចកសាងបាននូវចំណេះដឹងថ្មីៗជាបន្តបន្ទាប់, ចំណេះដឹងលើការរៀបចំស្ថានភាពរស់នៅ ឬ ការបណ្ដុះបណ្ដាលនានាលើផ្នែករកប្រាក់ចំណូល និង ការកសាងសមត្ថភាពនានាដែលជាមូលដ្ឋានជួយពួកគេអោយមានលទ្ធភាពដោះស្រាយបាននូវកត្តាទាំងឡាយដែលធ្វើអោយពួកគេក្លាយជាជនរងគ្រោះដូចជាអត្រា

កំណើនខ្ពស់នៃមរណៈភាពមាតា អំពើហឹង្សាក្នុងគ្រួសារ ការជួញដូរផ្លូវភេទ និង ការឆ្លងមេរោគហ៊ីវ/អេដស៍។

គេបានប៉ាន់ប្រមាណថាចំនួនប្រជាជនបច្ចុប្បន្ន មានប្រមាណ១៣លាននាក់ ហើយអត្រាកំនើនប្រជាជនប្រចាំឆ្នាំគិតជាមធ្យមគឺ ២.៤៩% ដូចនេះក្នុងរយៈពេល២៥-៣០ឆ្នាំខាងមុខ អត្រាប្រជាជននឹងកើនឡើងទ្វេ ។ ប្រជាជនដែលមានអាយុ១៨ឆ្នាំ និងអាយុក្រោមនេះគឺមាន៥២% នៃប្រជាជនសរុប។ មានប្រជាជន៣៦% រស់នៅក្រោមបន្ទាត់ក្រីក្រហើយស្ថានភាពសេដ្ឋកិច្ចសង្គមរបស់ក្រុមមនុស្សទាំងនេះរួមផ្សំដោយអនក្ខរជនដ៏ច្រើនលើសលប់ដែលក្នុងនោះរួមមានជនពិការ ស្ត្រីមេម៉ាយ ក្មេងកំព្រា ក្មេងតាមចិញ្ចើមថ្នល់ និងជនដែលងាយរងគ្រោះដទៃផ្សេងទៀត ។ អត្រាមរណៈកុមារមានចំនួន៩៥នាក់ក្នុងចំណោមក្មេង១០០០នាក់ ដែលទើបនឹងកើត (ហើយ១២៥នាក់ស្លាប់ក្នុងចំណោមក្មេង១០០០នាក់ ដែលមានអាយុក្រោម៥ឆ្នាំ ) ។ បន្ថែមលើសពីនេះទៅទៀត គេបានប៉ាន់ប្រមាណថា មានក្មេង៤៥% ដែលមានអាយុក្រោម៥ឆ្នាំ មិនបានទទួលទានអាហារគ្រប់គ្រាន់ ហើយប្រជាជនដែលឆ្លងមេរោគហ៊ីវក្នុងចំណោមអ្នកដែលចូលចិត្តរួមភេទគឺមាន៣.៧% (១៨០,០០០នាក់)។

## ១.២ កិច្ចប្រឹងប្រែងអភិវឌ្ឍន៍និងការយល់ដឹង

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាធានាដល់ប្រជាពលរដ្ឋគ្រប់រូបអោយទទួលបាននូវការអប់រំមូលដ្ឋាន៩ឆ្នាំ ហើយផែនការជាតិសំរាប់អប់រំទាំងអស់គ្នា២០០៣-២០១៥របស់រាជរដ្ឋាភិបាលបានផ្តល់នូវក្របខ័ណ្ឌការងារដើម្បីសំរេចអោយបាននូវការសន្យារបស់រដ្ឋធម្មនុញ្ញ ក៏ដូចជាបណ្តាគោលដៅនានានៃការអប់រំក្រៅប្រព័ន្ធ ។ ផែនការនេះសង្កត់ធន់ទៅលើការកែលំអគុណភាព និងប្រសិទ្ធិភាពនៃសេវាអប់រំ និងការពង្រីកឱកាសសិក្សាដល់ជនទាំងឡាយណាដែលជួបការលំបាក និងរស់នៅតំបន់ដាច់ស្រយាល។ ផែនការនេះដើរតួនាទីជាតំណាងអោយគោលការណ៍នានាក្នុងការផ្តល់ការអប់រំជាមូលដ្ឋានតាមរយៈការអប់រំក្នុងប្រព័ន្ធ និងការអប់រំក្រៅប្រព័ន្ធព្រោះថា ការផ្តល់ការអប់រំជាមូលដ្ឋាននេះ គឺជាទំនួលខុសត្រូវរបស់រាជរដ្ឋាភិបាលដោយមានការសហការយ៉ាងសកម្មពីសំណាក់ឪពុកម្តាយ សហគមន៍ និងសង្គមស៊ីវិល ក្នុងការធានាផ្តល់ជូននូវការសិក្សាមូលដ្ឋាន ៩ ឆ្នាំ ដល់ជនទាំងឡាយណាដែលជួបការលំបាកអោយទទួលបានឱកាសសិក្សាពេញលេញ និងស្មើភាពគ្នា។ នៅដើមឆ្នាំ២០០៣ គោលនយោបាយថ្នាក់ជាតិសំរាប់អប់រំក្រៅប្រព័ន្ធត្រូវបានអនុម័ត និងប្រកាសអោយប្រើដោយសម្តេចនាយករដ្ឋមន្ត្រីហ៊ុន សែន។



ទោះបីជាមានការយល់ព្រមលើគោលនយោបាយបែបនេះ និង ការទទួលស្គាល់ការអប់រំក្រៅប្រព័ន្ធ តាមវត្តអារាម ដែលជាប្រពៃណីប្រវត្តិសាស្ត្រក៏ដោយក៏នៅតែមានការវាយតំលៃមិនសមស្របទៅ

នឹងតួនាទីរបស់អប់រំក្រៅប្រព័ន្ធ ដែលត្រូវដើរតួនាទីក្នុងការចូលរួមអភិវឌ្ឍន៍ដ៏ទូលំទូលាយក្នុងក្របខ័ណ្ឌអប់រំសំរាប់ទាំងអស់គ្នា ។ ការគាំទ្រមិនពេញលេញ. ការប្រើប្រាស់មិនអស់លទ្ធភាព និងការសហប្រតិបត្តិការមិនគ្រប់គ្រាន់រវាងរាជរដ្ឋាភិបាល និង បណ្តាទីភ្នាក់ងារក្រៅរាជរដ្ឋាភិបាលនៅតែបន្ត។ ក្នុងចន្លោះឆ្នាំ១៩៩៤ដល់ឆ្នាំ១៩៩៩ ការគាំទ្រថវិកាសំរាប់អក្ខរ.កម្មបានកើនឡើងប្រហែលពី៣៦៥.០០០ ទៅ ២លានដុល្លាអាមេរិក ប៉ុន្តែចាប់ពីឆ្នាំ១៩៩៧ ការផ្តល់មូលនិធិពីរដ្ឋាភិបាលបានធ្លាក់ចុះ ដោយសារមូលនិធិមួយចំនួនត្រូវបានអង្គការក្រៅរដ្ឋាភិបាលនានាជាអ្នកផ្តល់ជំនួសអោយរដ្ឋាភិបាល ។ នៅក្នុងផែនការថ្នាក់ជាតិសំរាប់ការអប់រំទាំងអស់គ្នាបានបញ្ចូល១% នៃចំណាយចរន្ត និង ៨% នៃការចំណាយមូលធន ហើយនៅក្នុងគំរោង PAP បានរាប់បញ្ចូល៤.៤% សំរាប់វិស័យអប់រំ។

ចំនុចខ្លាំងនៃការអន្តរាគមន៍របស់ការងារអប់រំក្រៅប្រព័ន្ធស្ថិតលើសមត្ថភាពក្នុងការឆ្លើយតបទៅនិងស្ថាន ភាពរស់នៅជាក់ស្តែងរបស់ប្រជាជន (កុមារ យុវជន និង មនុស្សពេញវ័យ) ។ ផលប្រយោជន៍សំខាន់ៗ ៤យ៉ាងនៃអន្តរាគមន៍របស់ការងារអប់រំក្រៅប្រព័ន្ធមាន :

-"រៀនបណ្តើរ រកចំណូលបានចិញ្ចឹមជីវិតបណ្តើរ" *(មានន័យថា សិស្សអាចបន្តធ្វើការងាររបស់ខ្លួនទន្ទឹមគ្នានឹងការរៀនសូត្រ)*

-មានភាពទន់ភ្លន់ និង បត់បែន *(ទីកន្លែង ពេលវេលា សម្ភារៈ អ្នកបង្រៀន ។ល។)*

-ការប្រើប្រាស់ និង ការសំរបសំរួលនូវធនធាននៅក្នុងសហគមន៍ *(អ្នកបង្ហាត់នៅតាមអាគារសិក្សា ។ល។)* និង

-ការសន្សំសំចៃដោយសារតែមានអាគារ ដែលសង់សំរាប់គោលបំណងមានតិចតួច ហើយគេប្រើប្រាស់អ្នកបង្ហាត់ដែលយកប្រាក់ឧបត្ថម្ភទាប

-កាត់បន្ថយផ្ទាល់នូវភាពក្រីក្រ ពីព្រោះកម្មវិធីអប់រំក្រៅប្រព័ន្ធត្រូវបានរៀបចំឡើងជាបឋមសំរាប់អ្នកក្រីក្រជាងគេបង្អស់។

ប្រព័ន្ធអប់រំក្នុងប្រព័ន្ធគឺ ពិតជាមានសារៈសំខាន់ណាស់ ប៉ុន្តែប្រព័ន្ធអប់រំនេះតែឯងគឺមិនអាចឆ្លើយតបទៅ នឹងការប្រឈមមុខនៃការអប់រំដ៏មហិមាដែលប្រទេសកម្ពុជាកំពុងតែជួបប្រទះសព្វថ្ងៃនេះបានទេ។តំបន់ជាច្រើននៅទូទាំងប្រទេសជួបប្រទះនូវការខ្វះខាតចំនួនសាលារៀន រឺមិនមានថ្នាក់សិក្សាពេញកំរិត និងខ្វះខាតគ្រូបង្រៀន ។ កុមារ, យុវជន និងមនុស្សពេញវ័យរាប់សិបពាន់នាក់មិនមានលទ្ធភាពបោះបង់ពីការងាររបស់ពួកគេ ដើម្បីចូលរៀនតាមនិយាមសិក្សាពេញម៉ោងបានឡើយ (ទុកជាមានសាលាក្នុងប្រព័ន្ធមានក្នុងសហគមន៍របស់ពួកគេក៏ដោយ) ប្រទេសកម្ពុជា ក៏មិនអាចរង់ចាំរហូតដល់មានសាលារៀន ក្នុងប្រព័ន្ធនៅគ្រប់ទីកន្លែងនៅក្នុងទូទាំងប្រទេសបានឡើយ ។ បទពិសោធន៍ជាសកលបានបង្ហាញអោយឃើញថា ការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមនៃប្រទេសមួយអាស្រ័យទៅលើការបង្កើននូវអក្ខរកម្មវិជ្ជជីវៈដល់ប្រជាជនរបស់ខ្លួន ។ បើគ្មានអក្ខរកម្មសេដ្ឋកិច្ច "ថ្មី" មិនអាចសំរេចបានទេ ពីព្រោះថា សេដ្ឋកិច្ចថ្មីវាអាចកើតឡើងដោយផ្អែកទាំងស្រុងទៅលើប្រជាជនដែលបន្តរៀនសូត្រនូវជំនាញថ្មីៗ ដើម្បីឆ្លើយតបទៅនឹងតំរូវការនៃទីផ្សារជាតិ និង អន្តរជាតិ។ បើគ្មានអក្ខរកម្ម និង ការធ្វើវិមជ្ឈការរួមគ្នាទេ នោះការអភិវឌ្ឍន៍ផ្ទាល់ខ្លួននឹងប្រឈមមុខ និង ការរាំងរ៉

ជួនជួររួមមានសុខភាព និង អាហារូបត្ថម្ភចុះខ្សោយ និងពុំមានលទ្ធភាពគាំពារដល់ក្មេងៗ (ទាំងកត្តាសេដ្ឋកិច្ច និងកត្តាចិត្តសាស្ត្រ ) ទៅសាលារៀន។ ការអប់រំក្រៅប្រព័ន្ធគឺជាកូនសោរគន្លឹះក្នុងការដោះស្រាយនូវ "វដ្តនៃភាពក្រីក្រ" ដ៏កាចសាហាវដោយ ហេតុថា ចំណេះដឹងទាប ជំនាញតិច និងឥរិយាបថមិនគាប់ប្រសើរ ជាហេតុនាំទៅរកផលិតភាពទាប ។ ផលិតភាពទាបនេះ ជាហេតុបណ្តាលអោយមានប្រាក់ចំណូលទាប ហើយប្រាក់ចំណូលទាបនេះ ហើយដែលនាំអោយប្រជាជនមិនមានប្រាក់សន្សំ ដែលការនេះនាំទៅរកការគ្មានប្រាក់បណ្តាក់ទុនសំរាប់ការកែលំអផលិតភាព (តួយ៉ាងដូចជា ការអប់រំ ) ដែលទាំងអស់នេះ នឹងនាំពួកគេអោយវិលទៅរកភាពក្រីក្រជាបន្តទៅទៀត។

## ១.៣ គោលបំណងនៃផែនការសកម្មភាពអប់រំក្រៅប្រព័ន្ធ

កម្មវិធីអប់រំក្រៅប្រព័ន្ធនៅកម្ពុជាកំពុងត្រូវបានអនុវត្តន៍ដោយទីភ្នាក់ងាររដ្ឋាភិបាលអង្គការក្រៅរដ្ឋាភិបាល និងបណ្តាអង្គការសហគមន៍នានាយ៉ាងទូលំទូលាយ។ អាជ្ញាធរជាតិនឹងផ្តោតលើការបង្កើតឡើងនូវវត្ថុបំណងរួម និង វិធីសាស្ត្រនានាបន្ថែមលើការបណ្តុះបណ្តាល, ការសំរបសំរួល និង ការគាំទ្រដល់អាជ្ញាធរថ្នាក់ខេត្ត។ ការធ្វើផែនការគម្រលំអិត ជាក់ស្តែង ការជ្រើសរើស និងបណ្តុះបណ្តាលគ្រូបង្រៀន ព្រមទាំងការអនុវត្តនឹងកើត មានឡើងនៅកំរិតថ្នាក់ខេត្ត ស្រុក និងឃុំ ដោយសហការជាមួយបណ្តាអង្គការក្រៅរដ្ឋាភិបាលនានា ។ ផែនការសកម្មភាពសំរាប់ការអប់រំក្រៅប្រព័ន្ធកំពុងតែបង្កើតនូវគោលដៅ និងវត្ថុបំណង និង វិធីសាស្ត្រជាទូទៅ ដែលមានលក្ខណៈជាកម្មវិធី និងការចង្អុលបង្ហាញជាជាងការផ្តល់នូវការលំអិតគំរោងជាក់លាក់។

អង្គការក្រៅរដ្ឋាភិបាលជាដៃគូបានដើរតួយ៉ាងសំខាន់សំរាប់ជួយប្រជាជនដែលមានការលំបាក។

គោលបំណងជាមូលដ្ឋាននៃផែនការសកម្មភាពនេះមានពីរគឺ:

១. ដើម្បីផ្តល់នូវក្របខ័ណ្ឌទាក់ទងគ្នាមួយជាមួយនឹងរដ្ឋាភិបាល អង្គការក្រៅរដ្ឋាភិបាល និងសហគមន៍ ដើម្បីធ្វើផែនការ, រៀបចំការងារ, ត្រួតពិនិត្យ និងវាយតំលៃលើកម្មវិធីអប់រំក្រៅប្រព័ន្ធ, និង

២. ដើម្បីផ្តល់នូវក្របខ័ណ្ឌមួយដើម្បីកំណត់ នូវវចនាសម្ព័ន្ធ និង គោលនយោបាយអប់រំក្រៅប្រព័ន្ធ

## ១.៤ គោលដៅទូទៅ

អប់រំក្រៅប្រព័ន្ធមានតួនាទីយ៉ាងសំខាន់ក្នុងការបង្កើតឡើងនូវមូលដ្ឋានធនធានមនុស្ស ដើម្បីសំរេចអោយបាននូវគោលដៅជាតិ ដើម្បីសន្តិភាពការកាត់បន្ថយភាពក្រីក្រប្រកបដោយនិរន្តភាព ការរីកចំរើនខាងសេដ្ឋកិច្ច និង សមភាពសង្គម ។ គោលដៅអភិវឌ្ឍន៍ "**សហស្សវត្ស**" ត្រូវបានរដ្ឋាភិបាលទទួលយកហើយដាក់បញ្ចូលនូវកម្មវិធី កាត់បន្ថយភាពក្រីក្រកំរិតធន់ ការកែលំអក្នុងវិស័យសុខាភិបាល ការផ្តល់ឱកាសសិក្សា និងសមភាពយេនឌ័រ ។ កុមារ យុវជនមនុស្សពេញវ័យត្រូវការជាចំបាច់នូវជំនាញដើម្បីចូលរួម និង ទទួលផលប្រយោជន៍ពីការអភិវឌ្ឍន៍ជាតិជាទូទៅ និងពង្រឹងនូវគុណភាពជីវិតផ្ទាល់ខ្លួនរបស់ពួកគេ។

គោលដៅជាតិគឺប្ដេជ្ញាសំរេចអោយបាននូវការអប់រំសំរាប់ទាំងអស់គ្នាអោយបានត្រឹមឆ្នាំ២០១៥។ គោលដៅស្នូលទាំង៦ របស់ការអប់រំសំរាប់ទាំងអស់គ្នា គឺ:

១. ធានាថា នៅឆ្នាំ២០១៥ កុមារទាំងអស់ ជាពិសេសកុមារី កុមារដែលស្ថិតក្នុងកាលៈទេសៈលំបាក និង កុមារមកពីក្រុមជនជាតិភាគតិចបានទទួល និង បំពេញចប់នូវកាតព្វកិច្ចអប់រំបឋមសិក្សាដោយឥតបង់ថ្លៃ និង ប្រកបដោយគុណភាព។

២. ធានាថា តំរូវការរៀនសូត្ររបស់យុវវ័យ និងជនពេញវ័យគ្រប់រូបត្រូវបានដោះស្រាយតាមរយៈការផ្ដល់ឱកាសស្មើភាព ដើម្បីចូលរួមក្នុងកម្មវិធីសមស្រប និង ការបណ្ដុះបណ្ដាលចិញ្ចឹមជីវិត (បំណិនជីវិត)។

៣. ធានាសំរេចអោយបានការរីកចំរើនចំនួន ៥០% នៅក្នុងកំរិតអក្ខរកម្មជនពេញវ័យនៅមុនដំណាច់ឆ្នាំ២០១៥ ជាពិសេសសំរាប់ស្ត្រីភេទ និង ឱកាសស្មើភា ក្នុងការអប់រំមូលដ្ឋាន និង ការអប់រំបន្តសំរាប់ជនពេញវ័យ ទាំងអស់។

៤. លប់បំបាត់ភាពខុសគ្នានៃភេទក្នុងបឋម និង មធ្យមសិក្សាអោយបាននៅឆ្នាំ២០១៥ ដោយផ្ដោតការយកចិត្តទុកដាក់លើការធានាអោយកុមារីទទួលបានលទ្ធភាពចូលរៀនដោយពេញលេញ និងភាពស្មើភាពហើយ និង សំរេចអោយបាននូវការអប់រំមូលដ្ឋានមួយប្រកបដោយគុណភាព។

៥. ពង្រីក និង កែលំអការអប់រំ និង ថែទាំកុមារតូចអោយបានទូលំទូលាយ ជាពិសេសកុមារដែលជួបការលំបាក និងងាយទទួលរងគ្រោះបំផុត។

៦. កែលំអលើគ្រប់ទិដ្ឋភាពនៃការអប់រំនិងធានាបាននូវគុណភាពប្រសើរបំផុតគ្រប់ផ្នែក ដើម្បីអោយមនុស្ស គ្រប់រូបផលើម បានលទ្ធផលនៃការរៀនសូត្រដែលមានការទទួលស្គាល់ និង អាចវាស់វែងបានជាពិសេស ផ្នែកអក្សរសាស្ត្រ លេខនព្វន្ត និងជំនាញចាំបាច់សំរាប់ចិញ្ចឹមជីវិត (បំណិនជីវិត)។

កម្មវិធីអប់រំក្រៅប្រព័ន្ធក៏ដូចបណ្ដាកម្មវិធីនានាដែលស្ថិតនៅក្រោម **កម្មវិធីគាំទ្រផ្នែកអប់រំ** (ESSP) និង បណ្ដាកម្មវិធីដែលមានខាងក្រោមនឹងចូលរួមវិភាគទានយ៉ាងខ្លាំងក្លា ដើម្បីសំរេចនូវគោលដៅជាតិទាំងនេះ ដោយសហការជាមួយប្រព័ន្ធអប់រំក្នុងប្រព័ន្ធ។

## ១.៥ បណ្ដាអាទិភាពសំរាប់អប់រំក្រៅប្រព័ន្ធ

គេបានកំណត់នូវបណ្ដាគន្លឹះអាទិភាពចំនួន ៧ សំរាប់ការងារអប់រំក្រៅប្រព័ន្ធ។ អាទិភាពចំនួន ៥ ដំបូងគឺ ជាកម្មវិធីជាក់លាក់ ដែលផ្ដោតលើក្រុមមុខសញ្ញាដែលបានកំនត់រួចជាស្រេច។ កម្មវិធីទាំង៥ នេះមាន:

១. កម្មវិធីអក្ខរកម្មវិជ្ជាជីវៈសំរាប់យុវជន និង មនុស្សពេញវ័យ

២. កម្មវិធីសមមូលបឋមសិក្សា និង មធ្យមសិក្សា បឋមភូមិ សំរាប់កុមារនៅក្រៅសាលា យុវជន និង ជនពេញវ័យ

៣. កម្មវិធីបណ្ដុះបណ្ដាលជំនាញក្នុងការបង្កើនប្រាក់ចំណូលរយៈពេលខ្លីសំរាប់យុវជន និងមនុស្សពេញវ័យ

៤. កម្មវិធីក្រោយអក្ខរកម្មសំរាប់ជួយអោយមាននិរន្តភាព និងការពង្រីកកំរិតអក្ខរកម្មវិជ្ជាជីវៈ

៥. កម្មវិធីអប់រំគ្រួសារសំរាប់ការអភិវឌ្ឍន៍កុមារតូច កម្មវិធីជាអាទិភាពទី៦ និងទី៧ មានការពាក់ព័ន្ធនឹងការគាំទ្រដល់គ្រប់កម្មវិធី

៦. មជ្ឈមណ្ឌលសិក្សាសហគមន៍

៧. ការកសាងសមត្ថភាពសំរាប់ការដឹកនាំ និងគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព។

ក្នុងខណៈដែលសាលារៀនក្នុងប្រព័ន្ធប្រកបដោយគុណភាពខ្ពស់ប្រហែលជាត្រូវការពេលវេលាពី ២០ ទៅ៣០ឆ្នាំទៀត ដើម្បីអោយក្លាយជាសាលារៀនគំរូទូទៅសំរាប់ការសំរេចបាននូវការអប់រំជាមូលដ្ឋានសំរាប់កុមារ និងយុវជននោះការបង្កើតអោយមាននូវប្រព័ន្ធសាលារៀនដែលប្រកបដោយគុណភាពបែបនេះស្ថិតនៅលើផ្លូវដ៏វែងឆ្ងាយមួយ ហើយទន្ទឹមនឹងនេះគេមិនអាចបដិសេធន៍នូវសិទ្ធិរបស់កុមារ និងយុវវ័យក្នុងការទទួលសេវាអប់រំបានឡើយ ។ ស្របគ្នានេះដែរ គោលដៅរយៈពេលវែងនៃការកសាង និងការថែរក្សាប្រព័ន្ធអប់រំក្នុងប្រព័ន្ធមួយគំរូ អោយមានការលើកស្ទួយបរិស្ថានរៀនសូត្រសមរម្យ ពីសំណាក់ឪពុកម្តាយ និងពីជនដែលមានវ័យនៅក្មេង ហើយបានទទួលការអប់រំខ្ពស់ ព្រោះពួកគេទាំងនេះហើយដែលអោយតំលៃទៅលើប្រសិទ្ធិភាពនៃការអប់រំ ហើយគាំទ្រកូនៗរបស់ពួកគេ និងផ្តល់នូវពេលវេលា និងធនធានសំរាប់ការរៀនសូត្រ ។ គំរូនៃការអប់រំក្រៅប្រព័ន្ធសក្តិសម បំផុតសំរាប់ការផ្តល់មូលដ្ឋានអប់រំបែបនេះ។

## ១.៦ គោលការណ៍សកម្មភាព

ក្នុងក្របខ័ណ្ឌការងារនេះកម្មវិធីអប់រំក្រៅប្រព័ន្ធនឹងប្រតិបត្តិការក្រោមគោលការណ៍អន្តរទំនាក់ទំនង ៣ ។ ភាពរីកចំរើនក្នុងគោលការណ៍អន្តរទំនាក់ទំនងទាំងបីនេះ នឹងក្លាយជាលក្ខខ័ណ្ឌដ៏ចាំបាច់សំរាប់ធ្វើជាចលនាដ៏មានប្រសិទ្ធិភាពចំពោះបណ្តាសកម្មភាពនានា និងសកម្មភាពជាកណាត់មួយចំនួន។

**ការកំណត់នូវមុខសញ្ញាឡាស់លាស់សំរាប់កម្មវិធីអប់រំក្រៅប្រព័ន្ធ:** ប្រជាជនស្ទើរតែទាំងអស់យល់ ឃើញថាការរកទទួលទានសំខាន់ជាងការអប់រំ ហើយការយល់ឃើញនេះកំពុងតែកើនឡើង ។ អ្នកទាំងនោះរួមមានទាំង ប្រជាជនដែលរស់នៅក្នុងភាពក្រីក្រ និងក្រុមជនដែលគេបដិសេធន៍មិនអោយចូលរួមក្នុងវប្បធម៌សង្គមចំនួន៣៦% កុមារដែលមិនបានចុះឈ្មោះចូលរៀន ១៥% និង៤៧%នៃកុមារមិនបានរៀនចប់ថ្នាក់ទី៥ និង៣៧%នៃប្រជាជន ដែលមានអាយុលើស១៥ឆ្នាំ ដែលជាអនក្ខរជន ។ អ្នកទាំងអស់ខាងលើនេះ ភាគច្រើនលើសលប់កំពុងជាប់រវល់ក្នុងការរកផ្លូវរស់ និងចិញ្ចឹមជីវិតរបស់ពួកគេ ហេតុនេះហើយការអប់រំពេញម៉ោងមិនមែនជាជំរើសសំរាប់ពួកគេទេ។

ក្នុងចំណោមក្រុមប្រភេទមនុស្សដ៏ធំនេះ កម្មវិធីអប់រំក្រៅប្រព័ន្ធនឹងផ្តោតការយកចិត្តទុកដាក់ជាសំខាន់លើស្ត្រី និងក្មេងស្រី ជនពិការ ជនជាតិភាគតិច និងកម្មករចាកចេញពីស្រុកមករកការងារធ្វើនៅទីប្រជុំជន។

**ផែនការជាតិសំរាប់ការអប់រំទាំងអស់គ្នា :** បានកំណត់ផងដែរនូវតំរូវការចាំបាច់ជាអទិភាពខ្ពស់សំរាប់ហគមន៍ខ្មែរក្រហមដែលបានធ្វើសមាហរណកម្មកុមារ

និងមនុស្សជំទង់ដែលរស់នៅក្នុងតំបន់ក្រីក្រក្នុងទីក្រុង ទាហានរំសាយ និងគ្រួសាររបស់ពួកគេ ។ ការប្រើប្រាស់នូវឯកសារអង្កេតអក្ខរកម្ម ឯកសារអង្កេតភាពក្រីក្រ សុខភាព និងស្ថិតិជាតិដទៃទៀតដែលមានស្រាប់ និង " **ផែនទី** " អាចជួយជំរុញអោយការងារអប់រំក្រៅប្រព័ន្ធកាន់តែមានប្រសិទ្ធិភាពឡើងថែមទៀត ទៅលើមុខសញ្ញាដែលបានកំណត់រួចជាស្រេចហើយនោះ។

**ការធ្វើវិមជ្ឈការនៃកម្មវិធីអប់រំក្រៅប្រព័ន្ធៈ** រដ្ឋាភិបាលមានការប្តេជ្ញាចិត្តចំពោះដំណើរការកំណែទំរង់ប្រព័ន្ធអប់រំ ដែលកំពុងតែកើតមានឡើងដោយសង្កត់ធន់លើតំរូវការចំបាច់.ក្នុងចំនោមកម្មវិធីអាទិភាពនានា.ដើម្បីចេញផុតពីភាពរឹងកំព្រឹសនិងរចនាសម្ព័ន្ធអប់រំមជ្ឈការព្រមទាំងខ្លឹមសារក្នុងតាមបែបចាស់គំរិលឆ្ពោះទៅរកវិធីសាស្រ្ត តាមបែបវិមជ្ឈការ និងទន់ភ្លន់បត់បែនបានព្រមទាំងមានលក្ខណៈជាការអនុវត្តជាក់ស្តែងថែមទៀត។ការអប់រំក្រៅប្រព័ន្ធទាមទារជាពិសេសនូវក្របខ័ណ្ឌការងារវិមជ្ឈការដែលនឹងធ្វើអោយរាល់កម្មវិធីទាំងអស់អាច ឆ្លើយតបទៅនឹងតំរូវការយ៉ាងមានប្រសិទ្ធិភាពរបស់បណ្តាសហគមន៍មូលដ្ឋាន និងការចែករំលែកអំណាចអោយដល់បុគ្គល ដើម្បីចាត់ចែងនូវការរៀន និងការអភិវឌ្ឍន៍ផ្ទាល់ខ្លួនរបស់ពួកគេ។ អាជ្ញាធរថ្នាក់ជាតិនឹងបណ្តុះបណ្តាលអាជ្ញាធរថ្នាក់ខេត្ត ដើម្បីអោយចេះរៀបចំផែនការ និងគាំទ្រកម្មវិធីអប់រំក្រៅប្រព័ន្ធរបស់ពួកគេ។ ដូចគ្នានេះដែរ អាជ្ញាធរថ្នាក់ខេត្តនឹងបណ្តុះបណ្តាលអង្គភាពថ្នាក់ស្រុក ថ្នាក់ឃុំ និងថ្នាក់សហគមន៍ក្នុងការធ្វើផែនការ និងគាំទ្រពួកគេលើកម្មវិធីអប់រំក្រៅប្រព័ន្ធ។ នៅទីបំផុត "**មជ្ឈមណ្ឌលសិក្សាសហគមន៍**" ត្រូវកសាងឡើងនៅតាមវត្តអារាមក្នុងភូមិ វិអាគារវប្បធម៌ផ្សេងៗទៀត។

**ការធ្វើអោយប្រសើរឡើងនូវគុណភាពនៃការអន្តរាគមន៍របស់កម្មវិធីអប់រំក្រៅប្រព័ន្ធៈ** គុណភាពនៃលទ្ធផលនៃការរៀនសូត្រគឺជាបញ្ហាដ៏សំខាន់មួយក្នុងការសំរេចអោយបាននូវគោលដៅអប់រំក្រៅប្រព័ន្ធ ។ សំរាប់ការងារអប់រំក្រៅប្រព័ន្ធ. អាំងឌីកាទ័រវាយតំលៃជាគន្លឹះរួមមាន : គុណភាពនៃការទទួលបានការអប់រំ គុណភាពនៃលទ្ធផលរៀនសូត្រដែលសំរេចបាន និង គុណភាពនៃការអភិវឌ្ឍន៍ស្ថាប័ន ។ *ឧទាហរណ៍:*

*គុណភាពនៃការទទួលបានការអប់រំ* : ការចុះឈ្មោះចូលរៀនពិតប្រាកដសំរាប់កម្មវិធីមុខសញ្ញានីមួយៗ(ចំនួនអ្នកចូលរួម អាយុ ភេទ ជនជាតិភាគតិចកំរិតនៃភាពក្រីក្រ។ ល។ ) ឆ្លើយតប ទៅកម្មវិធីសិក្សាពេលវេលាសិក្សា និង អត្រាបញ្ចប់កម្មវិធី។

*គុណភាពនៃលទ្ធផលរៀនសូត្រដែលសំរេចបានៈ* តំរូវការសមត្ថភាពស្នូល. ភាពពាក់ព័ន្ធនឹងការរៀនសូត្រ (ឧទាហរណ៍: តើសកម្មភាពរៀនសូត្របាន "ធ្វើអោយមានការផ្លាស់ប្តូរ" ក្នុងការរស់នៅរបស់អ្នករៀន រឺទេ?). ភាពស័ក្តិសមនិងភាពបត់បែនទន់ ភ្លន់នៃវិធីសាស្រ្តបង្រៀន និង សំភារៈសិក្សា. រយៈពេល និង ប្រពលភាពនៃការចូលរួម ។

*គុណភាពនៃការអភិវឌ្ឍន៍ស្ថាប័នៈ* ប្រសិទ្ធិភាព និងការពាក់ព័ន្ធនៃការបណ្តុះបណ្តាល"បុគ្គលិក" (នៅគ្រប់កំរិត). ភស្តុតាងនៃការវាយតំលៃនូវតំរូវការដែលបានកែលំអ ការធ្វើផែនការ និង រៀបចំ នូវគ្រប់កំរិត) និង ចំនួននៃសកម្មភាពសហប្រតិបត្តិការដែលបានអនុវត្ត។

## ១.៧ រយៈពេលរួច

ផែនការសកម្មភាពអប់រំក្រៅប្រព័ន្ធបានគ្រប ដណ្តប់លើរយៈពេលចាប់ពីឆ្នាំ២០០៣-២០១៥ ។ រយៈពេលនេះ ត្រូវបានបែងចែកចេញជា ៣ ដំណាក់កាលៈ ផែនការរយៈពេលខ្លី ដល់២០០៥) ផែនការរយៈពេលមធ្យម (ដល់២០១០) និង ផែនការរយៈពេលវែង (ដល់ ២០១៥)។ ក្នុងន័យនេះទៅផែនការរយៈពេលខ្លីមាន លក្ខណៈជាការពង្រីកនូវសកម្មភាពនានា ដែលកំពុង អនុវត្តនាពេលបច្ចុប្បន្ន ប៉ុន្តែផ្តោតជាចំបងលើការ អភិវឌ្ឍ និង ការបន្សីកម្មវិធីទៅនឹងស្ថានភាពជាក់ ស្តែង ការកសាងកម្មវិធីសិក្សា សំភារៈរៀន និង បង្រៀន ការបណ្តុះបណ្តាល និង ការពង្រីកនូវ សមត្ថភាពក្នុងការផ្ទេរចំណេះដឹងលើកម្មវិធីអប់រំក្រៅ ប្រព័ន្ធ ។ ផែនការរយៈពេលមធ្យមមានចរិតជា ការ ពង្រីកអោយកាន់តែធំទូលាយនូវគ្រប់សកម្មភាពកម្ម វិធីអប់រំក្រៅប្រព័ន្ធទាំងអស់ និងការអនុវត្តនូវកម្មវិធី សមមូលនៅមធ្យមសិក្សាបឋមភូមិ។ ផែនការរយៈ ពេលវែងផ្តោតលើការសំរេចនូវគោលដៅអប់រំសំរាប់ ទាំងអស់គ្នា អោយបានពេញលេញសំរាប់អប់រំក្រៅ ប្រព័ន្ធ។

## ១.៨ ការប្រមូលធនធាន

កង្វះខាតដែលសកម្មការងារអប់រំក្រៅប្រព័ន្ធ កំពុងប្រឈមមុខគឺការមិនមានធនធានមនុស្ស និង ធនធានហិរញ្ញវត្ថុគ្រប់គ្រាន់ក៏ដូចជាសមត្ថភាពស្ថាប័ន នៅមានលក្ខណៈទន់ខ្សោយនៅឡើយ ក្នុងប្រទេស កម្ពុជានាពេលបច្ចុប្បន្ននេះទាំងក្នុងរដ្ឋាភិបាលនិងផ្នែក ក្រៅរដ្ឋាភិបាលក្នុងការឆ្លើយតបអោយបានគ្រប់គ្រាន់ ដល់តំរូវការរៀនសូត្រចាំបាច់ទាំងអស់របស់ប្រជាជន អោយបានទាន់ពេលវេលា។ ការគៀរគរធនធានដ៏ធំ មួយនឹងត្រូវការជាចាំបាច់ ដើម្បីសំរេចគោលដៅអប់រំ ជាតិអោយបាននៅត្រឹមឆ្នាំ២០១៥។ ការនេះនិងតំរូវ អោយមានការពង្រីកដ៏មហិមា លើសមត្ថភាពរបស់ អាជ្ញាធរជាតិ និង អាជ្ញាធរថ្នាក់ខេត្តដើម្បីបណ្តុះ បណ្តាល និងគាំទ្រដល់អង្គការថ្នាក់ស្រុកនិង ថ្នាក់ឃុំ-សង្កាត់។ធនធានមនុស្សខាងក្រៅបន្ថែម ដែលរួមមាន ធនធានមនុស្សមកពីអង្គការស្ម័គ្រចិត្តអាជីពជាតំរូវ ការចាំបាច់មួយ ហើយធនធានមនុស្សទាំងនេះត្រូវ ជួយលើការងារអប់រំក្រៅប្រព័ន្ធសំរាប់រយៈពេលជា ច្រើនឆ្នាំទៀត ។ អង្គការក្រៅរដ្ឋាភិបាលក្នុងពេល ថ្មីៗនេះបានស្ថិតនៅជួរមុខគេនៃការសាកល្បង និងអនុវត្តកម្មវិធីអប់រំក្រៅប្រព័ន្ធ ហើយអង្គការក្រៅ រដ្ឋាភិបាលទាំងនេះត្រូវការជាចាំបាច់នូវការពង្រីកកម្ម វិធីអប់រំក្រៅប្រព័ន្ធរបស់ពួកគេ ។ បន្ថែមលើនេះ សេចក្តីត្រូវការចាំបាច់ក្នុងការធ្វើអោយមានការកើន ឡើងនូវសកម្មភាពអប់រំក្រៅប្រព័ន្ធតំរូវអោយមានការ ផ្តល់មូលនិធិពីខាងក្រៅតាមរូបភាពពហុភាគី និង ទ្វេ ភាគី។

# ២. អក្ខរកម្មវិជ្ជាជីវៈសំរាប់មនុស្សពេញវ័យ

## ២.១. ស្ថានភាពទូទៅ

ក្នុងអត្ថន័យដ៏ពេញលេញនៃទស្សនៈទានមានប្រជាជនត្រឹមតែ៣៦% ប៉ុណ្ណោះ ដែលអាយុរបស់ពួកគេលើសពី១៥ឆ្នាំគឺជាអក្ខរជនវិជ្ជាជីវៈ ។ ចំនែកប្រជាជន ២៧% ផ្សេងទៀតត្រូវបានគេចាត់ទុកថា ជាជនដែលមានចំនេះដឹងស្មើនឹងពាក់កណ្តាលអក្ខរកម្ម ។ ដោយឡែក ប្រជាជន៣៧% ដែលនៅសល់គឺជាអនក្ខរជនសុទ្ធសាធ។អត្រាអក្ខរកម្មជាតិដែលក្នុងនោះរួមមានទាំងជនពាក់កណ្តាលអក្ខរកម្មបុរសភេទត្រូវបានគេប៉ាន់ស្មានថា មានចំនួន៧៩% ក្នុងខណៈដែលអត្រាអក្ខរកម្មជាស្ត្រីភេទវិញមានតែ៥៧% ប៉ុណ្ណោះគិតជាមធ្យម ។ មានភាពខុសគ្នាជាសក្តានុពលក្នុងប្រទេសរវាងតំបន់ជនបទ និងតំបន់ទីក្រុងហើយក្នុងនោះជនជាតិភាគតិចត្រូវបានគេសង្កេតឃើញថា ស្ថិតក្នុងលំដាប់ទាបជាងគេបង្អស់។ ខេត្តមួយចំនួនដូចជា ខេត្តស្ទឹងត្រែង មណ្ឌលគិរី ឧត្តរមានជ័យ ព្រះវិហារ កោះកុង និង រតនគិរី អត្រាអក្ខរជនស្ថិតនៅក្រោមមធ្យមភាគជាតិ (ស្ថិតក្នុងលំដាប់ឡើង ចំនួនអក្ខរជនចាប់ពី ២៣% ទៅ ៥៦%)។

ក្នុងប្រទេសកម្ពុជា ក្រុមអាយុអាទិភាពពី១៥-២៤ឆ្នាំត្រូវបានគេបានប៉ាន់ស្មានថាមានបុរសជាអនក្ខរជន ចំនួន ៤០០,០០០ នាក់ និងស្ត្រីជាអនក្ខរជនចំនួន ៧០០,០០០ នាក់ ។ ហើយក្រុមអាយុចាប់ពី២៥ ដល់ ៤៥ឆ្នាំ គេបានប៉ាន់ប្រមាណថាមាន១,២លាននាក់ជាអនក្ខរជន។ ការបណ្តុះបណ្តាលសមត្ថភាពសំរាប់អក្ខរកម្មវិជ្ជាជីវៈជនពេញវ័យក្នុងប្រទេសកម្ពុជានាពេលថ្មីៗនេះត្រូវបានគេប៉ាន់ថាបានធ្វើលើសិស្សប្រមាណ ៥០,០០០នាក់ក្នុង១ឆ្នាំ ។ លើសពីនោះទៅទៀតគ្រូអក្ខរកម្មតិចជាងពាក់កណ្តាលគឺជាស្ត្រីភេទ ដែលចំនួននេះបញ្ជាក់ន័យថា មានការខ្វះខាតខាងតួនាទីគំរូសំរាប់ស្ត្រីជាអនក្ខរជន។

## ២.២. ភាពសមហេតុផល

ភាពក្រីក្រនៅតែបន្តចំពោះមនុស្សពេញវ័យនិងយុវជនដែលងាយរងគ្រោះដោយសារតែកំរិតអក្ខរកម្មរបស់ពួកគេទាប រួមនិងការយល់ដឹងពីស្ថានភាពជីវិត និង ចំណេះដឹងពាក់ព័ន្ធនឹងជំនាញរបស់ពួកគេនៅមានកំរិតបានក្លាយទៅជាកត្តាបង្អាក់នូវសមត្ថភាពរបស់ពួកគេក្នុងការចូលរួម និង ទាញយកផលប្រយោជន៍ពីការរីកចំរើននៃសេដ្ឋកិច្ចសង្គមជាតិ ។ ចំណេះដឹង និងជំនាញដែលទាមទារអោយមនុស្សត្រូវធ្វើការក្នុងបែបផែនសេដ្ឋកិច្ច "ថ្មី" ឬដែលទាមទារអោយមនុស្សត្រូវចេះទាញយកផលប្រយោជន៍ពីទំនើបកម្មនៃសេដ្ឋកិច្ច កសិកម្មបែបប្រពៃណីស្ថិតនៅក្នុងកំរិតមួយនៅឡើយសំរាប់យុវជន និង មនុស្សពេញវ័យដែលជាអ្នកមិនមែនអក្ខរជនវិជ្ជាជីវៈ។ អនក្ខរជនជាស្ត្រីកំពុងស្ថិតនៅក្នុងការប្រថុយប្រថាន ជាពិសេសអំពីអត្រាកំណើតខ្ពស់ អំពីអត្រាមរណៈភាពនៃមាតា អំពីអំពើហិង្សាក្នុងគ្រួសារ អំពីការជួញដូរស្ត្រីភេទ និងការឆ្លងរាលដាលនៃមេរោគអេដស៍ (HIV/AIDS)។ ឳពុកម្តាយជាអក្ខរជនមានលទ្ធភាពល្អប្រសើរក្នុងរកប្រាក់ផ្គត់ផ្គង់ការរស់នៅ និង ចិញ្ចឹមបុត្រធីតារបស់ខ្លួន ជាពិសេសស្ត្រីជាម្តាយតែងបានគាំទ្រយ៉ាងពេញទំហឹង

នូវការសិក្សារបស់កូនៗ ហើយស្ត្រីដែលមានតួនាទីជាគ្រូបង្រៀន ឬជាអ្នកចាត់ចែងការងារអប់រំតែងជំរុញនូវបរិយាកាសរៀនសូត្រកុមារបានយ៉ាងរួសរាយ។



ការអភិវឌ្ឍន៍ធនធានមនុស្សនៅកំរិតបុគ្គលពាក់ព័ន្ធទៅនឹងដំណើរការរៀនសូត្រ និង ការចេះយកចំណេះដឹងដែលបានពីការរៀនសូត្រមកប្រើប្រាស់ដើម្បីកែលំអគុណភាពនៃជីវិត។ អក្ខរកម្មវិជ្ជាជីវៈគឺ ជាជំហានដំបូងដ៏មានសារៈសំខាន់បំផុតក្នុងដំណើរការរៀនសូត្រអំពីរបៀបរបបនៃការរៀនសូត្រ ។ អក្ខរកម្មវិជ្ជាជីវៈ សង្កត់ធ្ងន់លើជំនាញអក្ខរកម្មលេខនព្វន្តនិងបំនិនជីវិតដែលជាជំនាញចាំបាច់ដំបូងបំផុតសំរាប់ការអភិវឌ្ឍន៍ សេដ្ឋកិច្ច វប្បធម៌ និង សង្គមទាំងនៅកំរិតបុគ្គល និង គ្រួសារ (គ្របខ័ណ្ឌម៉ាក្រូ) ។ នៅកំរិតម៉ាក្រូសេដ្ឋកិច្ចគេឃើញមានទំនាក់ទំនងរវាងអក្ខរកម្មវិជ្ជាជីវៈនិងការកើនឡើងក្នុងប្រាក់ចំណូល ការបណ្តាក់ទុនផលិតភាព និងផលទុនជាតិ (GDP)។ នៅពេលដែលអក្ខរកម្មវិជ្ជាជីវៈត្រូវបានគេដាក់បញ្ចូលនូវកម្មវិធីអប់រំសុខភាព អាហារូបបត្ថម្ភ និង ការបង្កើនប្រាក់ចំណូលទំនាក់ទំនងរវាងអាយុមានការកើនឡើង ហើយអត្រាមរណៈភាពមាតា និងទារកបានថយចុះ ។ ប្រជាជនមួយចំនួនត្រូវការចាំបាច់នូវអក្ខរកម្មវិជ្ជាជីវៈដើម្បីត្រៀមខ្លួនដោះស្រាយនូវការលំបាកនានា ដែលពួកគេជួបប្រទះដូចជា ភាពក្រីក្រធ្ងន់ធ្ងរ ការចំណាកស្រុកពីជនបទចូលទីក្រុង ការផ្លាស់ប្តូរការងារនិងស្ថានភាពសង្គម លទ្ធភាពទទួលយកបាននូវពត៌មានថ្មីៗ និងលទ្ធភាពស្វែងរកទីផ្សារ។

## ២.៣. ចក្ខុវិស័យ

ប្រជាជនចំនួន ៣៦% រស់នៅក្រោមបន្ទាត់នៃភាពក្រីក្រ ហើយភាគច្រើនលើសលប់នៃចំនួននេះជាអនក្ខរជន។ នៅក្នុងក្រុមមនុស្សទាំងនេះ អទិភាពត្រូវបានផ្តល់អោយក្រុមមនុស្សដែលមានអាយុពី១៥-២៤ ឆ្នាំ ជាពិសេសស្ត្រី។ ក្រុមមនុស្សទាំងនេះតំណាងអោយប្រជាជនប្រមាណ៤៥%នៃអក្ខរជនក្នុងប្រទេសកម្ពុជា ។ ជាងនេះទៅទៀតសកម្មភាពនានាត្រូវបានគេប្រកាន់យក ដើម្បីក្រុមមនុស្សដែលគេមិនសូវយកចិត្តទុកដាក់ទាំងនេះ : តាមលក្ខណៈស្ថានភាពភូមិសាស្ត្រ (តំបន់ដាច់ស្រយាលដែលដង់ស៊ីតេប្រជាជនទាប និងតំបន់ភ្នំ) តាមស្ថានភាពបរិស្ថាន (ស្រុកដែលលិចទឹក ជំងឺគ្រុនចាញ់ខ្ពស់ តំបន់ដែលតែងតែរខានដោយមីន) តាមលក្ខណៈតំបន់ អស្ថិរភាព សង្គម (សហគមន៍តាំងទីលំនៅថ្មី និងសមាហរណកម្ម) តាមស្ថានភាពជីវិតរស់នៅ (កុមារពលកម្ម កុមារតាមចិញ្ចើមថ្នល់ ទាហានរំសាយ) តាមលក្ខណៈវប្បធម៌ (ជនជាតិភាគតិច)។ការធ្វើការចំរុះទៅលើក្រុមមនុស្សទាំងនេះ សកម្មភាពនានាត្រូវធានាអោយបានពេញទំហឹងទៅលើស្ត្រី និងជនពិការ ។ ក្រុមនេះក៏ជាគន្លឹះសំខាន់ផងដែរចំពោះអនាគតសេដ្ឋកិច្ចនិងសង្គមរបស់ប្រទេសកម្ពុជា ។ នៅក្នុងរយៈពេល១៣ឆ្នាំខាងមុខក្រុមមនុស្សទាំងនេះនឹងក្លាយជាឪពុកម្តាយ និងជាបេះដូងនៃកំលាំងពលកម្មសួលរបស់ប្រទេស។